**BMI0124**

# សម្ភាសន៍ជាមួយឈ្មោះ ពិន សាវួន ភេទស្រី អាយុ៥៦ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កងវ៉ាដា

## ស្រុកកំណើតនៅភូមិកំពង់គោ ឃុំពោធិបាន ស្រុកបាភ្នំ ខេត្តព្រៃវែង

## សព្វថ្ងៃរស់នៅភូមិថ្មដែកកេះ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ជា ផល្លា

## ១៧ទំព័រ

ផល្លាៈ អ្នកមីងឈ្មោះអីដែរអ្នកមីង?

សាវួនៈ ឈ្មោះពិន សាវួន ។

ផល្លាៈ ពិន សាវួន?

សាវួនៈ ចាស៎!

ផល្លាៈ មីងអាយុប៉ុន្មានដែរមីង?

សាវួនៈ អាយុ៥៦ឆ្នាំ ។

ផល្លាៈ មីងរស់នៅភូមិឃុំណាដែរមីង?

សាវួនៈ នៅភូមិកំពង់គោ ឃុំពោធិបាន ស្រុកបាធំ ។

ផល្លាៈ អាណ្ហឹងស្រុកកំណើត?

សាវួនៈ ចាស៎!

ផល្លាៈ ភូមិកំពង់គោ ឃុំ?

សាវួនៈ ឃុំពោធិបាន ស្រុកបាធំ ខេត្តកណ្តាល ។

ផល្លាៈ ចុះរាល់ថ្ងៃរស់នៅភូមិឃុំអីដែរមីង?

សាវួនៈ នៅនេះភូមិថ្មដែកកេះ ឃុំបន្ទាយឆ្មា ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

ផល្លាៈ ចុះមីងកាលជំនាន់លន់ នល់ មីងធ្វើអីដែរកាលជំនាន់ណ្ហឹង?

សាវួនៈ កាលជំនាន់លន់ នល់ ធ្វើកងទ័ព ។

ផល្លាៈ អ៎! កងទ័ពខ្មែរក្រហមមែនមីង?

សាវួនៈ ខាងខ្មែរក្រហម ។

ផល្លាៈ ចាស៎! ចូលធ្វើតាំងពីពេលណាមីង?

សាវ៉ូនៈ ចូលឆ្នាំ៧២ ។

ផល្លាៈ ចូល៧២ ចូលណ្ហើងគេហៅចូលឬក៏ម៉េចមីង?

សាវ៉ូនៈ ចូលណ្ហើងដូចថាមានគូរដណ្ដឹងចឹងគេឲ្យចូលធ្វើកងទ័ពមួយឆ្នាំបានគេឲ្យការ ទទួលគូរដណ្ដឹងណ្ហើងស្លាប់ទៅក៏ចេះតែនៅនឹងគេទៅ ។

ផល្លាៈ ភ្ជាប់ពាក្យពីកាលមីងចឹង?

សាវ៉ូនៈ កាលពីក្មេងៗដីដូនមួយ ។

ផល្លាៈ ចាស៎!

សាវ៉ូនៈ ដល់ចឹងទៅគេមិនឲ្យយើងការទេគេឲ្យយើងចូលធ្វើកងទ័ពបានមួយឆ្នាំគូរដណ្ដឹងណ្ហើងស្លាប់ទៅក៏ចេះតែនៅនឹងគេទៅណា៎កុមារដែរណ្ហើង ។

ផល្លាៈ កាលណ្ហើងអាយុប៉ុន្មានមីង៧១,៧២ណ្ហើង?

សាវ៉ូនៈ អាយុ១៣,១៤ណ្ហើង ។

ផល្លាៈ ហើយចុះគូរដណ្ដឹងម៉េចបានស្លាប់មីង?

សាវ៉ូនៈ ត្រូវគ្រាប់ ។

ផល្លាៈ គាត់ទាហានមែនមីង?

សាវ៉ូនៈ ធ្វើទាហានដែរ!

ផល្លាៈ ទាហានខ្មែរក្រហមឬលន់ នល់មីង?

សាវ៉ូនៈ ទាហានខាងខ្មែរក្រហម ។

ផល្លាៈ ទាហានខ្មែរក្រហម?

សាវ៉ូនៈ ចាស៎!

ផល្លាៈ គាត់ចូលទាហានមុនឬក៏មីងចូលមុន?

សាវ៉ូនៈ ចូលជំណាលគ្នា ។

ផល្លាៈ ចុះគាត់អាយុស្របាៗមីងទេ?

សាវ៉ូនៈ គាត់បង ឥលូវណ្ហើងគាត់ហាដាងហើយជិតហុកដែរហើយ កាលណ្ហើងនៅក្មេងៗ ។

ផល្លាៈ ចា៎! ចុះគូដណ្ដឹងមីងឈ្មោះអីដែរ?

សាវ៉ូនៈ ឈ្មោះចាន់ ណុប ។

ផល្លាៈ ចាន់ ណុប! ស្រុកភូមិជាមួយគ្នាមែនមីងនៅជាមួយគ្នា?

សាវ៉ូនៈ នៅជាមួយគ្នា ។

ផល្លាៈ កាលមុនមីងនៅខេត្តកណ្តាល ដល់ចូលព្រៃៗមីងណាកាលចូលធ្វើកងទ័ព?

សាវូនៈ នៅតែតាមភូមិអត់ដែលនៅព្រៃផង!

ផល្លាៈ តាមភូមិ?

សាវូនៈ ធ្វើពេទ្យណ្ហឹងបន្តិចទៅ ធ្វើកងទ័ពណ្ហឹងបន្តិចទៅ។

ផល្លាៈ ពេទ្យណ្ហឹងពេទ្យខ្មែរក្រហមមែនមីង?

សាវូនៈ ពេទ្យខ្មែរក្រហម។

ផល្លាៈ ធ្វើពេទ្យនៅពេទ្យណាមីង?

សាវូនៈ ពេទ្យនៅតែស្រុកខ្ញុំដែរណ្ហឹង។

ផល្លាៈ ពេទ្យស្រុក?

សាវូនៈ ចា៎!

ផល្លាៈ ចុះមីងបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

សាវូនៈ កាលពីក្មេងរៀនបានត្រឹមថ្នាក់ទី៧។

ផល្លាៈ ថ្នាក់ទី៧ច្រើនដែរ រៀននៅសាលាណាមីង?

សាវូនៈ នៅសាលាស្អីទេចង់ភ្លេចសាលាដែរហើយ។

ផល្លាៈ នៅខេត្តកណ្តាល?

សាវូនៈ ខ្ញុំមករៀននៅភ្នំពេញណ្ហឹង នៅភ្នំពេញ។

ផល្លាៈ អ៎!នៅភ្នំពេញតាំងពីតូច?

សាវូនៈ ចា៎! តាំងពីអាយុ៨ឆ្នាំ ជួបជុំបងប្អូននៅណ្ហឹង។

ផល្លាៈ ចុះឪពុកម្តាយមីង?

សាវូនៈ ឪពុកម្តាយនៅស្រុកនេះ។

ផល្លាៈ ចា៎! ចុះមីងមានបងប្អូនប៉ុន្មាននាក់?

សាវូនៈ មានបងប្អូនប្រុសពីស្រី៥ ទាំងអស់៧នាក់។

ផល្លាៈ ៧នាក់ ចឹងមីងកូនទីប៉ុន្មាន?

សាវូនៈ ខ្ញុំកូនទី២។

ផល្លាៈ ចា៎! កូនទី២ចឹងបានរៀនបានច្រើន។ ចឹងមីងខ្ញុំសូមបកទៅនិយាយកន្លែងដែលមីងចូលខ្មែរក្រហមណ្ហឹងគេឲ្យមីងធ្វើអីខ្លះហើយចូលម៉េចអីម៉េចមីងអាចរៀបរាប់ឲ្យបានក្បោះក្បាយបន្តិចបានទេមីង?

សាវ៉ូនៈ	កាលចូលជាកងទ័ពណ្ហឹង?

ផល្លាៈ	ចាំ! ដំបូងគេឲ្យយើងធ្វើអី?

សាវ៉ូនៈ	ដំបូងចឹងកាលគេវ៉ៃយើងនៅក្មេងគេឲ្យយើងរែកបាយ ។

ផល្លាៈ	កាល៧២ណ្ហឹងមានគេវ៉ៃគ្នាដែរមឹង?

សាវ៉ូនៈ	គេអ្នកធំៗ គេវ៉ៃតែខ្ញុំវានៅក្មេង ។

ផល្លាៈ	ពីណាវ៉ៃពីណា?

សាវ៉ូនៈ	ខាងខ្មែរក្រហមគេវ៉ៃលន់ នល់ ។

ផល្លាៈ	ចាំណ្ហឹងអើយ!

សាវ៉ូនៈ	កាលណ្ហឹងមិនលន់ នល់ធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ?

ផល្លាៈ	ចាំ!

សាវ៉ូនៈ	ចឹងទៅមិនកើតជាខ្មែរក្រហមវ៉ៃលន់ នល់?

ផល្លាៈ	ចាំ!

សាវ៉ូនៈ	ប៉ុន្តែបើគេចូលវ៉ៃយើងនៅតូចមិនរែកបាយឲ្យគេ គេឲ្យរែកបាយឲ្យគេ ។

ផល្លាៈ	រែកម្តងប៉ុន្មានទៅមឹង?

សាវ៉ូនៈ	រែកម្តងប្រាំមួយសងខាង ។

ផល្លាៈ	រែកប៉ុន្មាននាក់មឹង?

សាវ៉ូនៈ	រែកជួនកាលពីនាក់បីនាក់ ។

ផល្លាៈ	រែកទៅតាមសមរភូមិមែនមឹង?

សាវ៉ូនៈ	ណ្ហឹងអើយ!

ផល្លាៈ	សមរភូមិគេនៅណាមឹង?

សាវ៉ូនៈ	គេដូចថានៅភ្នំពេញគេដាក់មុខនៅភ្នំពេញទៅ យើងនៅក្រៅចឹង ។

ផល្លាៈ	ចឹងមឹងគ្រាន់តែជាអ្នករែកបាយទៅ?

សាវ៉ូនៈ	គ្រាន់តែរែកបាយឲ្យគេ ។

ផល្លាៈ	ចាំ! ហើយម៉េចទៀតមឹងធ្វើអីទៀតមឹង?

សាវ៉ូនៈ	ដល់ពេលជ័យជិនះទៅចូលដល់...

ផល្លាៈ	ចឹងរែកបាយតាំងពី៧២ដល់៧៥?

សាវ៉ូនៈ	ចាំ! ទោះបីជាចូលវ៉ៃនឹងគេក៏មិនឲ្យយើងចូលព្រោះយើងនៅតូច ។

ផល្លាៈ ចា៎!

សាវ៉ួនៈ បានតែរែកបាយ ។

ផល្លាៈ ចឹងកាលណ្ហឹងមានចែកជាកងជាអីនៅមីងកាលណ្ហឹង?

សាវ៉ួនៈ កងនៅតាមកងគេប៉ុន្តែយើងនៅតូចចឹងគេដាក់តាមផ្ទះបាយគេឲ្យយើងជញ្ជូនឲ្យកងទ័ពគេ ។

ផល្លាៈ ចុះអ្នកណាប្រធាន ប្រធានឈ្មោះអីដែរមីង?

សាវ៉ួនៈ ខ្ញុំភ្លេចឈ្មោះគេអស់ហើយ ។

ផល្លាៈ ចុះអ្នកនៅជាមួយ កុមារនៅជាមួយគ្នាអីមីងអត់ចាំដែរមីង?

សាវ៉ួនៈ ភ្លេចអស់ហើយ យើងនៅនោះបន្តិចនេះបន្តិចចឹងយើងមិនសូវចាំ ។

ផល្លាៈ ចា៎! ចុះគូដណ្តឹងមីងណ្ហឹងចូលធ្វើធ្វើអីគេដែរមីង?

សាវ៉ួនៈ ធ្វើកងទ័ពណ្ហឹង ។

ផល្លាៈ កងទ័ពខាងវៃហ្នឹងឬគ្រាន់តែជាអ្នករែកបាយ?

សាវ៉ួនៈ គេខាងវៃ ។

ផល្លាៈ ខាងវៃសមរភូមិមុខណ្ហឹងមីង?

សាវ៉ួនៈ ណ្ហឹងអើយ! ប៉ុន្តែមិនមែននៅកងជុំគ្នាទេគេវៃនៅខាងទន្លេកើតខាងទន្លេបាសាក់ ។

ផល្លាៈ ទន្លេបាសាក់? ទន្លេបាសាក់ភូមិឃុំអីមីង?

សាវ៉ួនៈ ភូមិឃុំខ្ញុំមិញណ្ហឹង ។

ផល្លាៈ ដដែល? ចុះមីងអត់មានដែលបានទៅវៃទៅអីទេមីង កាន់កាំភ្លើងកាន់អី?

សាវ៉ួនៈ ដល់តែជ័យជិនះហើយណ្ហឹង ។

ផល្លាៈ ជ័យជិនះហើយម៉េចទៀតមីង?

សាវ៉ួនៈ ជ័យជិនះហើយគេចូលដល់ការកសាងណ្ហឹងធ្វើស្រែណ្ហឹងគេ ធ្វើស្រែខាងខ្មែរក្រហមណា៎ ។

ផល្លាៈ ចា៎!

សាវ៉ួនៈ ធ្វើស្រែហើយលើកទំនប់ ។

ផល្លាៈ គេជម្លៀសមីងទៅណាខ្មែរក្រហម?

សាវ៉ួនៈ ដែលគេវៃលន់ នល់ទៅគេមិនជិនះភ្នំពេញ?

ផល្លាៈ ចា៎!

សាវ៉ួនៈ ដល់គេជិនះភ្នំពេញទៅខ្ញុំឡើងមកឯង ។

ផល្លាៈ គេជម្លៀសទៅណា ម៉ោភ្នំពេញហ្នឹងឬក៏ម៉េច បានន័យថាគេវៃគ្នាភ្នំពេញណ្ហឹងមីងម៉ោដែរ?

សារ៉ូនៈ ខ្ញុំម៉ោតាមគេដែរ ម៉ោតាមគេចូលម៉ោភ្នំពេញ ។

ផល្លាៈ ចា៎!

សារ៉ូនៈ ប៉ុន្តែអត់បានធ្វើអីនឹងគេទេ គេអ្នកនេះគេបកចាប់ទាហានចាប់អីទៅខ្ញុំគេឲ្យដើរដុតរូបអាសអាភាស គេឃើញរូបណាដូចថាមិនសមរម្យអីគេឲ្យខ្ញុំដើរដុតចោល ។

ផល្លាៈ ដើរដុតនៅតាមណា តាមផ្លូវឬមួយក៏ចូលផ្ទះចូលសំបែង?

សារ៉ូនៈ គេដុតយកពីផ្ទះទៅដាក់តាមកន្លែងដែលគេមិនឲ្យឆេះណា៎ មិនឲ្យឆេះដល់ផ្ទះយកមកដុតទៅរូបថតអាសអាភាសណ្ហឹង ។

ផល្លាៈ ហើយមីងមានឃើញច្រើនទេរូបថតណ្ហឹង?

សារ៉ូនៈ ច្រើនណា៎!

ផល្លាៈ រូបថតម៉េចទៅអាសអាភាស?

សារ៉ូនៈ ដូចថាប្រុសនឹងស្រីវាខូចនឹងគ្នាណ្ហឹងណា៎ ស្រីបនស្រីបាណ្ហឹងណា៎ ។

ផល្លាៈ ចា៎!

សារ៉ូនៈ មិនសមរម្យគេឲ្យយើងប្រមូលដាក់ដុត ។

ផល្លាៈ នៅទីតាំងណាមីងមានចាំទេ?

សារ៉ូនៈ ដែលប្រមូលដុតចោលណ្ហឹង?

ផល្លាៈ ចា៎!

សារ៉ូនៈ នៅភ្នំពេញទួលទំពូងយើងណ្ហឹង ។

ផល្លាៈ នៅទួកទំពូង?

សារ៉ូនៈ ចា៎! ឡើងមកដុតរូបថត ។

ផល្លាៈ ចឹងស្នាក់នៅណាមីងពេលដែលឡើងម៉ោវិញនៅភ្នំពេញ?

សារ៉ូនៈ ពេលដែលឡើងម៉ោបណ្តើរៗ ម៉ោពេលជ័យជំនះគេចូលនៅភ្នំពេញគ្រប់គ្នាណ្ហឹង ។

ផល្លាៈ ចា៎!

សារ៉ូនៈ ប៉ុន្តែមិនជាកាន់កាប់អីទេ បន្តិចទៅនៅកងទ័ព បន្តិចទៅនៅទីនេះនៅទីនោះ បន្តិចទៅចុះទៅស្រែបន្តិចទៅលើកទំនប់មិនជាមូលដ្ឋានអីទេ ។

ផល្លាៈ នៅខេត្តកណ្តាលណ្ហឹងប្រធានតំបន់គេឈ្មោះអីគេមីង?

សារ៉ូនៈ អត់ស្គាល់!

ផល្លាៈ ចុះមីងចូលតាំង៧២?

សាវ៉ូនៈ ដែលខ្ញុំម៉ោតាមកងពិសេសគេ ។

ផល្លាៈ កងពិសេសនៅឆ្នាំ៧០ប៉ុន្មានមីង?

សាវ៉ូនៈ ឆ្នាំ៧២ណ្ហឹង កងពិសេសដែលដើរវៃគ្រប់ខេត្តចឹងណា៎ ។

ផល្លាៈ មីងស្ថិតនៅក្នុងកងពិសេសតាំងពី៧២?

សាវ៉ូនៈ ណ្ហឹងអើយ!

ផល្លាៈ ចុះពីណាប្រធានកងប្រធានអី?

សាវ៉ូនៈ គេបែកគ្នាអស់ហើយគេផ្លាស់មួយដំណាក់ៗអត់ដែលនៅមូលគ្នាទាំងអស់ទេ ទៅគេចេញបែកជាក្រុមៗ ។

ផល្លាៈ មីងធ្លាប់ធ្វើនៅខាងប្រពន្ធប្រធានភូមិមិញថាមីងធ្លាប់ធ្វើខាងរ៉ាដាមែនមីង?

សាវ៉ូនៈ អ៎!សម័យកសាងទេ!

ផល្លាៈ សម័យកសាង?

សាវ៉ូនៈ សម័យកសាងណ្ហឹងសម័យដែលជ័យជំនះខ្មែរក្រហមណ្ហឹង ។

ផល្លាៈ នៅក្នុង៧៥មីងណោះ?

សាវ៉ូនៈ ណ្ហឹងអើយ! ដាំបាយដាំអីនៅក្នុងវង្វង់គេកងអាកាស ។

ផល្លាៈ កងរ៉ាដាណ្ហឹងនៅណាមីង?

សាវ៉ូនៈ នៅពោធិ៍ចិនតុង ។

ផល្លាៈ នៅពោធិ៍ចិនតុង? ណ្ហឹងអើយគេប្រាប់ថាមីងដឹងរឿងណ្ហឹងច្រើន ចឹងបន្ទាប់ពី៧៥ខ្មែរក្រហមយកជ័យជំនះភ្នំពេញហើយម៉េចទៀតមីងឲ្យមីងទៅណាទៅណីទៀត?

សាវ៉ូនៈ ដាំបាយឲ្យភ្ញៀវពួកចិនគេម៉ោជួយកសាងព្រលានកំពង់ឆ្នាំង ។

ផល្លាៈ ចា៎!

សាវ៉ូនៈ ចឹងទៅយើងដាំបាយឲ្យគេហូប ។

ផល្លាៈ ដាំនៅកំពង់ឆ្នាំងឬក៏នៅភ្នំពេញ?

សាវ៉ូនៈ ដាំនៅកំពង់ឆ្នាំង គេកសាងនៅកំពង់ឆ្នាំងព្រលានយន្តហោះណ្ហឹង ដាំបាយនៅកំពង់ឆ្នាំងកន្លែងស្រុកដល់នេះគេបែកមកដាំនៅជិតព្រលានណ្ហឹងមិនដឹងស្រុកអីខ្ញុំមិនសូវស្គាល់ ។

ផល្លាៈ ដឹងតែនៅខេត្តកំពង់ឆ្នាំង ។

សាវ៉ូនៈ ណ្ហឹងអើយដឹងតែកំពង់ឆ្នាំង ។

ផល្លាៈ ចា៎!

សាវ្ងូនៈ តែឥលូវគេប្រើការអីអត់ខ្ញុំអត់ដឹងចិនគេជួយមកកសាង ។

ផល្លាៈ កសាងហើយឬអត់មីង?

សាវ្ងូនៈ កសាងអត់ទាន់ហើយទេ ចុះយួនចូលស្រុកចិនគេទៅស្រុកគេវិញទៅ ។

ផល្លាៈ ចឹងកសាងព្រលានកំពង់ឆ្នាំងតាំងពី៧៥ដល់៧៩ទេចឹងអត់ទាន់ហើយ?

សាវ្ងូនៈ អត់ទាន់ហើយ!

ផល្លាៈ ចឹងមីងដាំបាយនៅកំពង់ឆ្នាំងហើយធ្វើអីទៀតមីង?

សាវ្ងូនៈ យួនចូលស្រុកទៅខ្ញុំក៏ឈប់ធ្វើសង្គ្រាមទៅ ខ្ញុំដើរគេថាកន្លែងពេទ្យអីចឹងខ្ញុំទៅជ្រកកោនកន្លែងគេ ។

ផល្លាៈ ចុះមីងក្រែងថាធ្លាប់ធ្វើពេទ្យខ្មែរក្រហមដែរមីង?

សាវ្ងូនៈ ណ្ហឹងដល់ដំណាក់កាលណ្ហឹងពេទ្យខ្មែរក្រហមទៀត ប៉ុន្តែពេទ្យកាលណ្ហឹងជាសមាជិកគេទេវាមិនចេះអីទេគ្រាន់តែលាងរបួសលាងអីគេប្រើឲ្យធ្វើអីធ្វើណ្ហឹង ។

ផល្លាៈ ចឹងធ្លាប់រៀនពេទ្យគេមានបង្រៀនអីអត់ខ្មែរក្រហមមានដែលបង្រៀនយើងទេ?

សាវ្ងូនៈ គេថាអនុវត្តជាក់ស្តែង ដូចថារបួសអីយើងមើលគេគេលាងបើថាយើងមិនចេះគេអូសយើងទៅនេះទៅនោះចឹងយើងចេះតែខំទៅណា៎ ។

ផល្លាៈ ចា៎!

សាវ្ងូនៈ មើលគេខំធ្វើប្រឹងប្រែងបន្តិចទៅ ។

ផល្លាៈ ចឹងបន្ទាប់ពីខ្មែរក្រហមបែក ខ្មែរក្រហមបានជ័យជំនះហើយមីងទៅកំពង់ឆ្នាំងណ្ហឹងមីងដាំបាយឲ្យគេ?

សាវ្ងូនៈ ដាំបាយ!

ផល្លាៈ កងណ្ហឹងពីណាគេប្រធានមីង?

សាវ្ងូនៈ កងណ្ហឹង....

ផល្លាៈ ចុះមីងមិនមែនប្រធានអីទេ មែនប្រធានកងនារីទេមីង?

សាវ្ងូនៈ ខ្ញុំអត់ប្រធានទេ!

ផល្លាៈ ម៉េចចឹង?

សាវ្ងូនៈ ម៉ោពីខ្ញុំនៅមន្ទីរ ។

ផល្លាៈ មន្ទីរម៉េចមីង?

សាវ្ងូនៈ មន្ទីរ៥០២ មន្ទីរដូចថានៅកងពលគេក្តាប់ផ្ទាល់ចឹងណា៎ អត់បាននៅកងណ្ហឹងគេ ។

ផល្លាៈ មន្ទីរ៥០២! ចុះបាយទឹកម្ហូបអីហូបគ្រប់គ្រាន់ទេមីង?

សារ៉ូនៈ ខាងខ្ញុំអត់ខ្វះខាតអីទេ ។

ផល្លាៈ ហើយមន្ទីរ៥០២ណ្ហឹងពីណាអ្នកគ្រប់គ្រង?

សារ៉ូនៈ លោក ម៉េត ។

ផល្លាៈ លោក ម៉េត?

សារ៉ូនៈ ខាងកងអាកាស ។

ផល្លាៈ មីងមានដែលជួបលោកម៉េតណ្ហឹងផ្ទាល់ទេមីង?

សារ៉ូនៈ សព្វថ្ងៃណ្ហឹង?

ផល្លាៈ អត់ទេអាកាលមីងនៅធ្វើការជាមួយគាត់?

សារ៉ូនៈ ជួបតើ!គាត់ចុះផ្ទាល់ ។

ផល្លាៈ ជួបផ្ទាល់ហើយគាត់ម៉េចដែរមីង?

សារ៉ូនៈ គាត់អត់អីទេ! សព្វថ្ងៃគាត់នៅគ្រប់គ្រងខាងព្រលានបាត់ដំបងដែរ ។

ផល្លាៈ អ៎!លោកម៉េតណ្ហឹងមីង?

សារ៉ូនៈ ចា៎!

ផល្លាៈ ចុះអនុប្រធានពីណាគេមីង?

សារ៉ូនៈ លោកផល លោកផលណ្ហឹងនៅគ្រប់គ្រងខាងសំឡូត ។

ផល្លាៈ ចុះក្រោមការគ្រប់គ្រងរបស់គាត់យ៉ាងម៉េចដែរមីង ការគ្រប់គ្រងរបស់នៅគាត់នៅក្នុងមន្ទីរ ៥០២?

សារ៉ូនៈ អត់មានអីផង បើផ្ទៃក្នុងគេយ៉ាងណាៗគេមិនឲ្យយើងដឹងទេណា៎ រឿងវាសាមញ្ញធម្មតាតែបើខ្ញុំ គេអត់ធ្វើបាបទេណា៎ ។

ផល្លាៈ ចុះកាលណ្ហឹងគេឲ្យតួនាទីមីងជាអីគេ គេហៅអីគេមីង?

សារ៉ូនៈ ខ្ញុំ?

ផល្លាៈ ចា៎! នៅមន្ទីរ៥០២?

សារ៉ូនៈ ខ្ញុំនៅមន្ទីរ៥០២ណ្ហឹងអត់មានគ្រប់គ្រងអីទេ ដូចទទួលគ្រប់គ្រងពីលោកម៉េតណ្ហឹងហើយ ។

ផល្លាៈ ចា៎!

សារ៉ូនៈ ជាមួយក្រុមចឹងណា៎ មួយក្រុមណ្ហឹងស្មើរគ្នាទាំងអស់អត់មានអ្នកណាគ្រប់គ្រងអ្នកណាទេ ដូចថាគ្រប់គ្រងខាងលើផ្ទាល់ចឹងណា៎ ។

ផល្លា៖ ចាំ! ចឹងម៉ាមន្ទីរណ្ហឹងមានប៉ុន្មាននាក់ ម៉ាក្រុមណ្ហឹងមានសមាជិកប៉ុន្មាននាក់?

សារ៉ូន៖ ច្រើនណាស់! មន្ទីរណ្ហឹងខាង៥០២ក៏គាត់អ្នកគ្រប់គ្រងផ្ទាល់ដូចជាអ្នកបើកយន្តហោះ អ្នកកាត់ ដេរ អ្នកដាំបាយគាត់គ្រប់គ្រងផ្ទាល់ ។

ផល្លា៖ ចាំ! ចុះអត់ដែលឃើញសម្លាប់ឃើញអីទេមីង?

សារ៉ូន៖ អត់! ខ្ញុំអត់ដែលឃើញ ។

ផល្លា៖ នៅភ្នំពេញមីង?

សារ៉ូន៖ ខ្ញុំដែលចេញពីភ្នំពេញម៉ោខ្ញុំនៅកំពង់ឆ្នាំង នៅកំពង់ឆ្នាំងរហូតដល់យួនចូលស្រុក ។

ផល្លា៖ ចឹងនៅកំពង់ឆ្នាំងណ្ហឹងអត់មានអីទៀតទេមីង អត់មានប្រធានសហករណ៍ឈ្មោះអីៗទេមីង?

សារ៉ូន៖ អត់ទេខ្ញុំអត់ស្គាល់ប្រធានសហករណ៍ទេ បើគេនៅតាមភូមិចឹងគេបាននៅតាមសហករណ៍ ខ្ញុំនៅតាមដូកង៍ទ័ពអត់មានសហករណ៍ទេ ។

ផល្លា៖ ចាំ! នៅដូកង៍ទ័ព ចុះមានបានកាន់កាំភ្លើងកាន់អីទេមីង?

សារ៉ូន៖ (សើច)

ផល្លា៖ ព្រោះនៅកងកន្លែងខ្លះគេឲ្យយើងកាន់កាំភ្លើងដើម្បីការពារខ្លួន?

សារ៉ូន៖ តែយើងមិនចេះបាញ់គ្រាន់តែកាន់ៗ យើងនៅក្មេង ។

ផល្លា៖ គេឲ្យយើងកាន់ដែរមីងណោះ?

សារ៉ូន៖ យើងនៅក្មេងគ្រាន់តែកាន់ៗ ។

ផល្លា៖ កាន់ណ្ហឹងយាមនៅណាដែរមីង?

សារ៉ូន៖ កាន់ណ្ហឹងយាមតែខ្លួនណ្ហឹង ដេកយប់ចឹងទៅយាម តែមិនមានឃើញបាញ់ស្អីណាផងអត់មានអ្នកណាម៉ោផងចេះតែយាមៗជាទម្លាប់ចឹងទៅ ។

ផល្លា៖ ចាំ!

សារ៉ូន៖ ជំនាន់ណ្ហឹងបើចំពោះគេខ្ញុំមិនដឹងទេ បើខ្ញុំដូចអត់មានជួបការលំបាកអីទេដូចជាអត់បាយអត់ទឹកអីណ្ហឹងដូចជាអត់ជួបទេព្រោះអីថាយើងនៅកន្លែងភូមិភាគណាំ គេហៅភូមិភាគណ្ហឹងអ្នកគ្រប់គ្រងខាងលើចឹងណាំចឹងអត់ដែលចុះតាមសហករណ៍តាមភូមិអីទេអត់ដែលឃើញប្រជាជនទេ ។

ផល្លា៖ នៅខាងភូមិភាគហ្នងមីង?

សារ៉ូន៖ ចាំ!

ផល្លា៖ ភូមិភាគអីគេមីង?

សាវួនៈ ភូមិភាគពិសេស យើងអត់ដែលឃើញប្រជាជន អត់ដែលទៅគ្រប់គ្រងប្រជាជនធ្វើបាបប្រជាជនអីអត់ដែលទេ ។

ផល្លាៈ ចាំ!

សាវួនៈ គិតតែពីរឿងកសាង កសាងដូចជាធ្វើស្រែ ឧបត្ថម្ភទៅខាងប្រជាជនខាងក្រោយ សហករណ៍ណាខ្វះខាតចឹងទៅគេស្នើរសុំយើងឲ្យទៅគេចឹងណាំ ប៉ុន្តែកងគេផ្សេងខ្ញុំអត់ដែលបានធ្វើទេ ។

ផល្លាៈ ចឹងមីងមានដែលបានចុះទៅតាមភូមិឃុំដើម្បីទៅឧបត្ថម្ភអីទេមីង អត់ដែលណាំមីង?

សាវួនៈ អត់ដែលបានទៅទេ គ្រាន់តែថារៀបនឹងដឹកខោអាវដើម្បីទៅចែកជូនប្រជាជនឃួនគេចូលម៉ោខ្ញុំរត់ ។

ផល្លាៈ ខោអាវហ្នឹងមានកន្លែងធ្វើខោអាវរោងចក្ររោងអីដែរ?

សាវួនៈ អត់មានទេ ខោអាវដែលប្រជាជនរត់ចោលហ្នឹងប្រជាជនខាងក្រោយដែលគ្នាអត់ខ្លាំងក៏យើងប្រមូលទៅគួកឲ្យស្អាតបត់ឲ្យស្អាតឲ្យគេផ្សេងគេដើរចែក ។

ផល្លាៈ ចាំ!

សាវួនៈ ដើរចែកគាត់ពួកខោអាវសំណល់ពីដើមព្រោះអត់ទាន់មានរោងចក្រ ។

ផល្លាៈ ចុះមីងពេលខ្មែរក្រហមចូលមោឆ្នាំ៧៥ហ្នឹងបងប្អូនមីង ឪពុកម្តាយមីងទៅនៅណាវិញ?

សាវួនៈ ខ្មែរក្រហមចូលម៉ោម៉ែខ្ញុំគាត់នៅឯស្រុកណោះ គេអត់ធ្វើបាបគាត់ដែរព្រោះគាត់មានកូនចូលធ្វើកងទ័ព គេអត់ធ្វើបាបគាត់ទេ ។

ផល្លាៈ ចុះបងប្អូនមីងអត់អីទេ អត់មានស្លាប់មានអីទេមីង?

សាវួនៈ ស្លាប់តែជំនាន់សង្គ្រាម បើអីមួយដែលខ្ញុំនៅជាមួយនៅភ្នំពេញហ្នឹងបាត់រកគ្នាអត់ឃើញតាំងពីខ្ញុំនៅក្មេងរហូតទាល់សព្វថ្ងៃហ្នឹងក៏មិនទាន់រកគ្នាឃើញ ។

ផល្លាៈ ជំនាន់សង្គ្រាមហ្នឹងជំនាន់ណាមីង?

សាវួនៈ ជំនាន់៧៥ ខ្ញុំនៅជុំគាត់ខ្ញុំម៉ោពីស្រុកឯនេះ ហើយកាលជំនាន់ខ្មែរក្រហមខ្ញុំម៉ោស្រុកម៉ែខ្ញុំទៅយកម៉ោដល់ពេលនេះទៅមិនឯករាជ្យខ្ញុំអត់បានទៅរកគាត់ ដែលយើងចូលស្រុកហ្នឹងបានទៅរកបងប្អូន ។

ផល្លាៈ ចឹងកាលពេល៧៥ហ្នឹងម្តាយឪពុកមកយកមីងទៅខេត្តកណ្តាលហ្នឹង

សាវួនៈ ចាំ! យកពីភ្នំពេញទៅ ។

ផល្លាៈ ចាំ! ហើយដល់ពេលមីងថាធ្វើនៅកំពង់ឆ្នាំងហ្នឹងម៉េចវិញ?

សាវួនៈ អាហ្នឹងយើងជ័យជំនះ ។

ផល្លា: ជ័យជំនះ៧០ប៉ុន្មានមីង?

សារ៉ូន: ជ័យជំនះដូចថាខ្មែរក្រហមវ៉ៃលន់ នល់ឈ្នះឆ្នាំ៧៥ ។

ផល្លា: ចុះឪពុកម្ដាយថាមកយកៗឆ្នាំប៉ុន្មានវិញមីង?

សារ៉ូន: យកតាំងពី៧២ ។

ផល្លា: ឆ្នាំ៧២? ដល់ពេល៧២ណ្ហឹងបានចូលខ្មែរក្រហមហើយធ្វើពេទ្យធ្វើអី?

សារ៉ូន: ទៅនោះគេមិនឲ្យយើងនៅផ្ទះទេ គេឲ្យបែកពីម៉ែឪបងប្អូនទាំងអស់ណ្ហឹង ។

ផល្លា: ចា៎!

សារ៉ូន: នៅតែចាស់ៗក្មេងៗគេទៅធ្វើកងទ័ព ខ្លះគេទៅធ្វើពេទ្យ ធ្វើពេទ្យតាមក្រសួងមន្ទីរ ។

ផល្លា: ចឹងមីងដំបូងធ្វើពេទ្យហើយបានទៅលើកបាយលើកអីណ្ហឹង?

សារ៉ូន: ចា៎! ចូលក្នុងជួរទៅគេឲ្យវែកបាយ ដល់ជ័យជំនះ៧៥គេឲ្យទៅដាំបាយទៀត ។

ផល្លា: ចុះកាលដឹងថាគូរដណ្ដឹងស្លាប់ណ្ហឹងស្លាប់ដោយសារអីមីង?

សារ៉ូន: កាលវ៉ៃគ្នាជំនាន់នេះណ្ហឹង ។

ផល្លា: ម៉េចបានមីងដឹង? គេប្រាប់មែនមីង?

សារ៉ូន: គេប្រាប់! គាត់ស្លាប់បានមួយឆ្នាំពីរឆ្នាំហើយណ្ហឹងបានគេប្រាប់ ។

ផល្លា: ចា៎! ហើយអត់ឈឺចាប់អីទេមីង?

សារ៉ូន: ធម្មតាៗ ។

ផល្លា: អត់បានការ!

សារ៉ូន: អត់បានការ!

ផល្លា: ចឹងមីងជួរមកនៅបន្ទាយឆ្មានេះពីកាល់?

សារ៉ូន: ខ្ញុំម៉ោតាំងពីឆ្នាំណាទេអត់ចាំ ខ្ញុំម៉ោតាំងពីកូនខ្ញុំអាយុ៦ឆ្នាំឥលូវវា២០ហើយណ្ហឹង អត់ចាំឆ្នាំ ។

ផល្លា: ឥលូវ២០ចឹង១៨ឆ្នាំ ៨០ជាងហើយមីងណោះ?

សារ៉ូន: បោះឆ្នោតហើយ បោះឆ្នោតហើយ៩០ប៉ុន្មាន?

ផល្លា: ៩០ជាងហើយ!

សារ៉ូន: ៩១ដឹង ៩២ដឹងខ្ញុំអត់ចាំ ខ្ញុំអត់បានកត់ ។

ផល្លា: នៅជំនាន់ខ្មែរក្រហមណ្ហឹងមីងធ្វើអីខ្លះក្រៅពីនៅភូមិភាគពិសេសណ្ហឹង?

សារ៉ូន: អត់បានធ្វើអីទៀតផង! កាប់សម្លាប់គេក៏ខ្ញុំមិនដែល គ្រាន់ថាគេឲ្យដាំបាយឲ្យគេ ។

ផល្លា: បាយមួយថ្ងៃប៉ុន្មានពេលមីង?

សាវ៉ូនៈ បីពេល ពេលព្រឹក ពេលថ្ងៃត្រង់នឹងពេលល្ងាច ។

ផល្លាៈ ដាំឲ្យពួកចិនណ្ហឹងចេះខ្មែរឬអត់?

សាវ៉ូនៈ ចិនណ្ហឹងអត់ចេះខ្មែរទេតែមានអ្នកបកប្រែ ។

ផល្លាៈ អ៎! មានអ្នកបកប្រែ? ចិនឬខ្មែរអ្នកបកប្រែណ្ហឹង?

សាវ៉ូនៈ ខ្មែរពីមកពីប្រទេសចិនដែរ ។

ផល្លាៈ មកពីប្រទេសចិនតែចេះខ្មែរ?

សាវ៉ូនៈ រៀនទៅគេបក ។

ផល្លាៈ ចិនណ្ហឹងប៉ុន្មាននាក់?

សាវ៉ូនៈ កាលណ្ហឹងគេថា៥០០នាក់ ។

ផល្លាៈ ចិនសុទ្ធ?

សាវ៉ូនៈ ចិនសុទ្ធ ។

ផល្លាៈ ចុះធ្វើព្រលានកំពង់ឆ្នាំងណ្ហឹងមានខ្មែរយើងជួយដែរអត់មឹង?

សាវ៉ូនៈ មាន!

ផល្លាៈ ខ្មែរខ្លះចិនខ្លះ?

សាវ៉ូនៈ គេគ្រាន់តែខាងបច្ចេកទេស កម្លាំងធ្វើខ្មែរ ប៉ុន្តែគេឈប់វ៉ៃទៅគេកសាង អាណ្ហឹងកសាងគេលែងវ៉ៃហើយគេដាក់ទុកអាវុធទៅគេកសាង ។

ផល្លាៈ អ៎! ចុះមឹងមានដែលជួបចិនណ្ហឹងផ្ទាល់ទេ មានដែលនិយាយលេងជាមួយចិនណ្ហឹងទេ?

សាវ៉ូនៈ និយាយលេងដូចតែនេះណ្ហឹង តែវាស្តាប់គ្នាអត់បានគ្រាន់តែធ្វើដៃធ្វើជើង គាត់ចេះបន្តិចៗ ។

ផល្លាៈ ចិនណ្ហឹងក្មេងៗឬមួយក៏ចាស់មឹង?

សាវ៉ូនៈ អាយុប្រហែលសាមសែណ្ហឹង ហាហុកក៏មានដែរ ។

ផល្លាៈ មានស្រីមានប្រុសដែរមឹង?

សាវ៉ូនៈ អត់ទេ! អត់មានស្រីទេ!

ផល្លាៈ មានតែប្រុសសុទ្ធ?

សាវ៉ូនៈ ចា៎!

ផល្លាៈ ចុះមឹងមានដែលជួបអៀង ធារិទ្ធអីទេមឹង អៀង សារីអីមានដែលទៅមើលទេ?

សាវ៉ូនៈ អត់ដែលឃើញទៅទេ ព្រោះអីបើគេទៅជួបៗតែមេយើងខាងលើទេ យើងដូចថាឋានៈទាបៗចឹងគេអត់ដែលឲ្យឃើញទេ ។

ផល្លា៖	អត់ដែលឃើញទេមីងណោះ?

សារ៉ូន៖	ណ្ហឹងអើយ! អត់ដែលស្គាល់ពូតែគេថាប៉ុល ពត ប៉ុន្តែមិនដែលដឹងថាមុខគេណ្ហឹងម៉េចផង! ពូតែឈ្មោះដែរណ្ហឹង ។

ផល្លា៖	ចុះមីងចូលខ្មែរក្រហមណ្ហឹងមីងពេញចិត្តនឹងខ្មែរក្រហមដែរអត់មើលទៅ?

សារ៉ូន៖	កាលជំនាន់តស៊ូណ្ហឹងយើងអត់ដឹងទេ មិនដឹងថាអានេះនយោបាយគេ គេឲ្យយើងអ្នកកម្មករកសិករតស៊ូរំដោះដូចថាវ៉ៃកំចាត់នាយទុនសកដះភូមិចឹងណាំ ។

ផល្លា៖	ចាំ!

សារ៉ូន៖	គេយកនយោបាយណ្ហឹងមកអប់រំយើងចេះតែទៅនឹងគេទៅ បើយើងមិនទៅគេធ្វើបាបយើងគេអត់ពេញចិត្តទេ ។

ផល្លា៖	ចាំ!

សារ៉ូន៖	ព្រោះអីឡើយណាស់ អត់ដូចកាលយើងនៅពីក្មេងយើងហូបយើងចុក យើងរៀនយើងសូត្រគិតទៅជំនាន់ណ្ហឹងសីហនុហើយណោះ?

ផល្លា៖	ចាំ!

សារ៉ូន៖	យើងសប្បាយ យើងហូបគ្រប់គ្រាន់ដល់ទៅចូលចំណោមគេធ្វើតែការមានស្ងួវមានស្លឹស៊ី ។

ផល្លា៖	ចាំ!

សារ៉ូន៖	បើថាហូបបាយហូបតែបាយទៅ មានចំនីចំណុកអី ។

ផល្លា៖	មីងរៀនបានច្រើនដែរ?

សារ៉ូន៖	ខ្ញុំកាលទៅនៅជុំអ៊ីខ្ញុំគាត់ធ្វើការខាងធនាគារទៅ គាត់ឲ្យធ្វើការផ្ទះផងគាត់ឲ្យរៀនផង ។

ផល្លា៖	ចាំ!

សារ៉ូន៖	ជំនាន់ណ្ហឹងមិនស្ងួវវេទនាទេដល់យួនចូលស្រុកហើយបានខ្ញុំវេទនា វេទនារឿងអាមានគ្រួសារហើយណ្ហឹងបែកគ្នា បែកគ្នាទៅ..

ផល្លា៖	មីងមានគ្រួសារពីកាលមីង?

សារ៉ូន៖	កាលខ្ញុំមានគ្រួសារឆ្នាំ៨៥ ។

ផល្លា៖	ចុះអាជំនាន់៧៧ ៧៨ណ្ហឹងអត់អីទេមីង?

សារ៉ូន៖	អត់អីទេ!

ផល្លា៖	៧៧ ៧៨ណ្ហឹងជំនាន់ខ្មែរក្រហម ។

សាវ៉ូនៈ គេថាជួបការលំបាក ប៉ុន្តែខ្ញុំអត់ដែលទេ បើជួបៗតែប្រជាជនដូចថាចំរុះគេយកពីនេះទៅដឹកនាំ នោះអានោះដឹកនាំអានេះចេះតែធ្វើបាបគ្នាតៗទៅណា៎ ។

ផល្លាៈ ចា៎! ចុះពេលណ្ហឹងគ្នាមីងអត់មានពីណាផ្ទាស់ទៅណាទៅណីទេមីង អ្នកធ្វើការជាមួយមីងនៅកំពង់ឆ្នាំងណ្ហឹង?

សាវ៉ូនៈ បែកគ្នាអស់ហើយ ស្លាប់អស់ហើយ ដល់យួនចូលម៉ោគេរើសពួកខ្ញុំណ្ហឹងឲ្យទៅវៃម្តងទៀត ដល់ហើយទៅទៅគេកាន់កងកាន់អីទៅខ្ញុំរត់មកនៅពេទ្យ ខ្ញុំថាខ្ញុំឈប់ធ្វើហើយ ។

ផល្លាៈ ឈប់ធ្វើខ្មែរក្រហម?

សាវ៉ូនៈ ចា៎! មើលទៅដូចជាវេទនាខ្លាំងណាស់ ខ្ញុំឈប់ធ្វើណ្ហឹង៧៩ណ្ហឹងឯង ៧៩ណ្ហឹងខ្ញុំចេះតែវេសវេសទៅគេតាមរកខ្ញុំបើសិនជារកឃើញគេវៃចោលបាត់ហើយ ប៉ុន្តែខ្ញុំវេសមកនៅជុំៗពេទ្យទៅ ។

ផល្លាៈ ពេទ្យណ្ហឹងនៅណាមីង?

សាវ៉ូនៈ ពេទ្យណ្ហឹងពេទ្យកងពលដែលខ្ញុំនៅណ្ហឹងដែរ ។

ផល្លាៈ កងពល៥០២ណ្ហឹង?

សាវ៉ូនៈ ណ្ហឹងអើយ! ពេទ្យដែលរត់បែកគ្នា ដល់ជួបគ្នាខ្ញុំមកនៅជុំ ហើយដែលចាប់ឲ្យធ្វើកងទ័ពទៀតណ្ហឹងកងទ័ពគេផ្សេងដូចជាតំបន់ភូមិភាគពាយ័ព្យអីចឹងណា ។

ផល្លាៈ ចា៎!

សាវ៉ូនៈ គេចាប់យើងឲ្យជួយវៃយួនចឹងទៅ ខ្ញុំថាឈប់មើលទៅដូចជាកម្លាំងគេវាច្រើនឯងតិចវាខ្សោយ ថាឈប់ធ្វើបណ្តោយសុខចិត្តដាក់ខ្លួនធ្វើជាប្រជាជន ។

ផល្លាៈ ចុះមីងទៅនៅពេទ្យណ្ហឹងមីងទៅធ្វើពេទ្យមែនមីង?

សាវ៉ូនៈ នៅពេទ្យណ្ហឹងបើគេរស់គេឈឺអីណ្ហឹងជួយមើលគេ ។

ផល្លាៈ អ៎! មានរបួសមានអីដែរ?

សាវ៉ូនៈ មាន! ចុះគេវៃគ្នាមិនយកមកដាក់នៅកន្លែងពេទ្យ ។

ផល្លាៈ ចា៎!

សាវ៉ូនៈ យើងជួយមើល ប៉ុន្តែដែលយើងមិនសូវចេះចឹងភាគច្រើនៗតែជាំបាយណ្ហឹង ដាំបាយឲ្យអ្នកជម្ងឺហូប ។

ផល្លា៖ ច្រើនទេអ្នកជម្ងឺមីង?

សាវ៉ូន៖ ច្រើន៥០ ១០០រហូតដល់២០០អីណោះ ។

ផល្លា៖ ពេទ្យណ្ហឹងមើលតែខ្មែរក្រហមទេណោះ ព្រោះពេទ្យរបស់ខ្មែរក្រហម?

សាវ៉ូន៖ ចាំ!

ផល្លា៖ វ៉ៃជាមួយវៀតណាម?

សាវ៉ូន៖ វ៉ៃជាមួយវៀតណាម ប៉ុន្តែកាលណ្ហឹងមិនចាំតែយួនទេ ជួនកាលភូមិភាគដូចជាពាយ័ព្យ បច្ចឹម អីឃើញគ្នាអត់បានទេ ។

ផល្លា៖ ម៉េចចឹងមីង?

សាវ៉ូន៖ ដឹងតែវ៉ៃហ្នង

ចេះតែចោទគ្នាថាខាងនេះក្បត់ខាងនោះក្បត់ប៉ុន្តែមិនដឹងថាខាងណាក្បត់ទេណា៎ ។

ផល្លា៖ ចាំ!

សាវ៉ូន៖ ហើយពួកខ្ញុំនេះអត់ចេញមុខទេ ពួនៗក្នុងព្រៃណា៎ ។

ផល្លា៖ ចាំ!

សាវ៉ូន៖ វ៉ៃគេក៏មិនវ៉ៃចេះតែភាសៗខ្លួនទៅ អត់មានតាំងខ្លួនថាជាកងទ័ពទៅវ៉ៃគេអ្នកផ្សេងទេ បើថាចូលជាពេទ្យជាអីជួយរុំរបួសជួយមើលគេមើលអីណ្ហឹងជួយ បើថាជាវ៉ៃជាអីណ្ហឹងឈប់ហើយលែងវ៉ៃតាំងពី៧៩មេស៉ ។

ផល្លា៖ ចុះនៅភូមិភាគពិសេសណ្ហឹងនៅខេត្តកំពង់ឆ្នាំងឬខេត្តណាមីង?

សាវ៉ូន៖ ភូមិភាគពិសេសណ្ហឹងអត់ប្រចាំខេត្តទេ ។

ផល្លា៖ អត់ប្រចាំខេត្តទេ?

សាវ៉ូន៖ ភូមិភាគណាក៏ទៅបានដែរ ។

ផល្លា៖ តែអាណ្ហឹងទីតាំងវានៅណាភូមិភាគពិសេសណ្ហឹង?

សាវ៉ូន៖ អត់មានទីតាំងនៅទីនោះមួយខែចឹងទៅទៀតគ្រប់ខេត្តអត់បានទៅតែស្វាយរៀងទេ ចុះទៅតែខាងខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ ខត្តុង កំពង់លួង ។

ផល្លា៖ គេហៅទៅណ្ហឹងទៅវ៉ៃមែនមីង?

សាវ៉ូន៖ គេហៅទៅវ៉ៃ ។

ផល្លា៖ ទៅវ៉ៃចឹងមីងអត់ទៅទេឬក៏ទៅដែរ?

សាវ៉ូន៖ ទៅនឹងគេដែរតែគេអត់ឲ្យវ៉ៃទេឃើងវានៅក្មេងដែររាងសប្បាយ ។

ផល្លា៖ កាលណ្ហើងដូច១៧ដែរណ្ហើង?

សារ៉ូន៖ ១៧ ប៉ុន្តែជិនាញខាងនៅផ្ទះបាយគេឲ្យអត់ឲ្យយើងទៅមុខទេ។

ផល្លា៖ ចុះមីងកាន់កាំភ្លើងអីដែរអត់ មានអត់មីង?

សារ៉ូន៖ កាំភ្លើងបើគេនៅតាមកន្លែងកាលណ្ហើងគេឲ្យយើងកាន់តើ គេឲ្យយើងទុកដាក់ការពារខ្លួននោះ ប៉ុន្តែបាញ់ប្រោះអីមិនដែលចេះបាញ់ណា។

ផល្លា៖ គេអត់មានដែលបង្រៀនបាញ់ទេមីង?

សារ៉ូន៖ អត់ទេ!

ផល្លា៖ ចុះមន្ទីរ៥០២ណ្ហើងនៅក្នុងកងពលអីមីង?

សារ៉ូន៖ កងពល១១។

ផល្លា៖ មានវរៈសេនាអីទេមីង វរៈសេនាតូចធំអី?

សារ៉ូន៖ វរៈសេនាតូច កាលខ្ញុំនៅវរៈសេនាតូចលេខប៉ុន្មានហើយទេ ដល់បែកយូចឹងទៅភ្លេចហើយ។

ផល្លា៖ ចា៎!មីង

សារ៉ូន៖ ប្រហែល៤០ឆ្នាំហើយមើលទៅ។

ផល្លា៖ ៣០ ៤០សិបឆ្នាំហើយ។

សារ៉ូន៖ ភ្លេចហើយសូម្បីតែមិត្តភ័ក្ត្រដែលធ្លាប់នៅជុំគ្នាទោះជួបគ្នាក៏មិនស្គាល់។

ផល្លា៖ ចា៎! បែកគ្នាយូហើយ!

សារ៉ូន៖ យូហើយ។

ផល្លា៖ ចឹងក្រោយពីបែក៧៩ហើយមីងធ្វើអីទៀតទៅចឹង?

សារ៉ូន៖ បែក៧៩ហើយខ្ញុំអត់ធ្វើអីផង ខ្ញុំចូលធ្វើខាងនៅជាមួយប្រជាជន ឈប់ធ្វើទ័ពធ្វើហើយគេអ្នកមុខគេចេះតែវើទៅ គិតតែបែកពីម៉ែឪណ្ហើងសុំប្រជាជនធ្វើម៉ែធម៌ដ៏ចឹងទៅនៅភូមិឃុំគាត់។

ផល្លា៖ នៅភូមិឃុំណាមីងពេលទៅនៅណ្ហើង?

សារ៉ូន៖ នៅភូមិណ្ហើងគេហៅភូមិឡាក់៧០។

ផល្លា៖ នៅស្រុកខេត្តណាមីង?

សារ៉ូន៖ នៅទល់ដែនថៃ។

ផល្លា៖ នៅទល់ដែនថៃមីង?

សារ៉ូន៖ ចា៎!

ផល្លា៖ បន្ទាយមានជ័យឬខេត្តមានជ័យមីង?

សាវ៉ូនៈ   ទីនោះឬ?

ផល្លាៈ   ចា៎! ឆ្ងាយដែរមីងពីកំពង់ឆ្នាំងពីនេះទៅ  ដើរទៅរហូតពុអត់ទេមីង?

សាវ៉ូនៈ   ដែលជាមួយប្រជាជនណ្ហឹង?

ផល្លាៈ   ចា៎!

សាវ៉ូនៈ   ឆ្ងាយណា៎ម៉ោងនេះទៅហើយ  ពីឡាក់៧០ម៉ោងដីថៃងនេះទៅហើយ ។

ផល្លាៈ   ម៉េចបានមីងម៉ោនេះបឹងមីង?

សាវ៉ូនៈ   ដើរតាមៗគេចេះតែម៉ោតាមគេរហូត  គេថាទៅស្រុកថៃៗទៅខ្ញុំម៉ោ  គេដើរមួយខែដល់ខ្ញុំដើរ ឡើង៣ខែ ។

ផល្លាៈ   ៣ខែ?

សាវ៉ូនៈ   ៣ខែហូបតែស្លឹកឈើអត់ដែលស្គាល់បាយទេមកដល់ស្រុកថៃ  ។

ផល្លាៈ   អញ្ចឹងសូមអរគុណមីងច្រើន ។

«ចប់»